**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ២៦៩ សរណ.អករ

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបញ្ឈប់ការចេញអាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងផ្លូវទឹករបស់ក្រសួងទេសចរណ៍

យោងតាមសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ៣៦ សជណ.ហធ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ក្រសួងទេសចរណ៍មានកិត្តិយសសូមជម្រាបជូនដំណឹងដល់**សមាគមដឹកជញ្ជូនទេសចរណ៍ និងលោក-លោកស្រីជាម្ចាស់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងផ្លូវទឹកទាំងអស់** មេត្តាជ្រាបដូចខាងក្រោម៖

១. ក្រសួងទេសចរណ៍នឹងបញ្ឈប់ការចេញអាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងផ្លូវទឹកចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ តទៅ

២. អាជ្ញាបណ្ណទេសចរណ៍សម្រាប់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងផ្លូវទឹកចេញដោយក្រសួងទេសចរណ៍កន្លងមកដែលនៅមានសុពលភាព អាចបន្តអនុវត្តរហូតដល់អស់សុពលភាព

៣. លោក-លោកស្រីជាម្ចាស់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងផ្លូវទឹកដែលមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរផ្តល់ដោយក្រសួងសាធារណការនិងដឹកជញ្ជូន គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រកបអាជីវកម្មដឹកជញ្ជូនទេសចរណ៍ ដោយពុំចាំបាច់តម្រូវឱ្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ថែមទៀតទេ

៤. ដោយឡែក ម្ចាស់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងផ្លូវទឹកនៅតែអាចស្នើសុំចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងគុណភាពសេវាកម្ម ឬដាក់ពាក្យចូលរួមការប្រឡងប្រណាំងផ្សេងៗកម្រិតថ្នាក់ជាតិ ឬថ្នាក់តំបន់តាមរយៈក្រសួងទេសចរណ៍បាន។

ចំពោះព័ត៌មានបន្ថែម សូមមេត្តាទំនាក់ទំនងលេខទូរស័ព្ទលេខ **០៩២ ៧៧៩ ៨៣៣ ឬ០១២ ២៩៨ ៩៥៤ ឬ០១៥ ៧៧៧ ៨០៨**។

អាស្រ័យហេតុនេះ សូម **សមាគមដឹកជញ្ជូនទេសចរណ៍ និងលោក-លោកស្រីជាម្ចាស់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងផ្លូវទឹកទាំងអស់** មេត្តាជ្រាប និងអនុវត្តតាមសេចក្តីជូនដំណឹងនេះតាមការគួរ។

**ក្រសួងទេសចរណ៍**

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- សមាគមឧស្សាហកម្មទេសចរណ៍
- ឯកសារ កាលប្បវត្តិ